# ការបញ្ជូនទៅរក ការពិនិត្យ
# វិនិច្ឆ័យមើលការស្តាប់សម្លេង



**California Newborn Hearing Screening PROGRAM**

State of California, Department of Health Services,
Children's Medical Services

## តើហេតុអ្វី បានជាកូនរបស់ខ្ញុំត្រូវការ ការពិនិត្យវិនិច្ឆ័យមើល ការស្តាប់សម្លេង (Diagnostic Hearing Evaluation)?

កូនរបស់លោកអ្នក មិនបានជាប់ការពិនិត្យមើលការស្តាប់សម្លេង នោះទេ ។ មានវត្ថុជាច្រើនដែលអាចជ្រៀតជ្រែកក្នុងការពិនិត្យការស្តាប់សម្លេង, ឧទាហរណ៍, សម្លេងនៅក្នុងបន្ទប់ ឬទារកដែលរពឹស ។ វាជាការសំខាន់ណាស់ ដើម្បីឲ្យមានការធ្វើតេស្តខាងការស្តាប់សម្លេងយ៉ាងពេញលេញថែមទៀត ក្នុង ពេលឆាប់ៗដែលអាចធ្វើបាន ដើម្បីសម្រេចឲ្យដឹងថា កូនរបស់លោកអ្នកអាចឮ សម្លេងបានល្អ ប៉ុណ្ណា ។

## តើមានទារកប៉ុន្មាននាក់ ដែលមានការបាត់បង់ខាងការស្តាប់ សម្លេង?

ទារកភាគច្រើន កើតមកដោយមានការស្តាប់សម្លេងជាធម្មតា ។ ក៏ប៉ុន្តែ ការបាត់បង់ការស្តាប់សម្លេងយ៉ាងធ្ងន់ធ្ងរ ត្រូវបានគេរកឃើញ នៅក្នុងចំនួនទារកទើបប្រសូត ១-៤នាក់ក្នុងចំណោម ១000នាក់ ។ ប្រហែលជា ៥0 ភាគរយនៃចំនួនទារកដែលបានបាត់បង់ការស្តាប់សម្លេង ឥតមានសញ្ញា ឬកត្តាគ្រោះថ្នាក់អ្វីទេ, ដូចជាជម្ងឺធ្ងន់ ឬប្រវត្តិគ្រួសារ ។ មានលក្ខណៈជាច្រើន ដែលអាចកើតឡើង មុនពេលកំណើត, ក្នុងកំឡុងពេលទារក ឬក្នុងកុមារភាព ដែលអាចប៉ះពាល់ការស្តាប់របស់កុមារម្នាក់ ។ ការបាត់បង់ការស្តាប់សម្លេង ពេលក្រោយក្នុងកុមារភាព អាចជាលទ្ធផលនៃរោគដំបៅត្រចៀកជាបន្តបន្ទាប់, រោគរលាកស្រោមខួរក្បាល, របួសក្បាល ឬ រោគអ្វីៗផ្សេងទៀត ។ ថ្នាំសង្គ្រោះជីវិត ក៏អាចបណ្តាលឲ្យបាត់បង់ការស្តាប់សម្លេង ។ ពេលខ្លះ គ្មានអ្នកណា ម្នាក់ អាចដឹងអំពីមូលហេតុ ដែលបណ្តាលឲ្យបាត់បង់ការស្តាប់សម្លេងទេ ។ សូមពិគ្រោះជាមួយនិងវេជ្ជបណ្ឌិតរបស់កូនលោកអ្នក បើសិនជាលោក អ្នកមានសំណួរ ឬការព្រួយបារម្ភណ៍អ្វីមួយ ។

## តើហេតុអ្វី បានជាត្រូវធ្វើតេស្តទារក?

ការរកឃើញហេតុការណ៍ដែលបណ្តាលឲ្យបាត់បង់ការស្តាប់សម្លេង គួរតែធ្វើឡើងឲ្យបានឆាប់បំផុត ដែលអាចធ្វើបាន ។ ខែទីមួយនៃជីវិតរបស់កុមារម្នាក់ គឺជាការសំខាន់ណាស់ សម្រាប់ការលូតលាស់ខាងតិរិះពិភាក្សា ។ ទារកម្នាក់ដែលមានការបាត់បង់ខាងការស្តាប់សម្លេង ឬថ្លង់ អាចមានការលំបាក ក្នុងការបណ្តុះបណ្តាលតិរិះវិជ្ជាភាសា ឬមិនអាចរៀនបានល្អ ។ បើសិនជា គេអាចសំគាល់ការបាត់បង់ការស្តាប់សម្លេង ពីវ័យក្មេងជាង គេអាចផ្តល់នូវជំនួយដែលត្រូវការ បានយ៉ាងឆាប់ជាង ។

## អ្វីៗដែលលោកអ្នកអាចធ្វើដើម្បីត្រៀមខ្លួនសម្រាប់ការពិនិត្យវិនិច្ឆ័យមើលការស្តាប់សម្លេង" (Diagnostic Hearing Evaluation) របស់កូនលោកអ្នក

កូនរបស់លោកអ្នក ត្រូវការគេងឲ្យបានស្រួល ក្នុងកំឡុងពេលការពិនិត្យវិនិច្ឆ័យមើលការស្តាប់សម្លេង ។ យោបល់ទាំងនេះ ប្រហែលជាអាចជួយលោកអ្នក ត្រៀមខ្លួនដើម្បីជួយឲ្យកូនរបស់លោកអ្នក សម្រាកបានស្រួល ៖

1. សូមព្យាយាមកុំឲ្យកូនរបស់លោកអ្នក គេងមុនពេលកំណត់ ទៅជួប ។
2. បំបៅកូនរបស់លោកអ្នក មុនពេលធ្វើតេស្ត អាចជួយធ្វើកូននោះងងុយគេង ។
3. សូមយកភួយ, ដាយពីរបន្ថែម, ខោអាវបំឡាស់, និងទឹកដោះ បន្ថែម, បើប្រើ ។
4. លោកអ្នកអាចដាក់ពេលកំណត់ជួបរបស់កូនលោកអ្នក នៅពេលណាដែលកូនរបស់លោកអ្នក អាចងងុយគេង ។



## តើមានអ្វីនឹងកើតឡើង បន្ទាប់ពីការពិនិត្យមើល?

លោកអ្នកនឹងត្រូវគេប្រាប់អំពីលទ្ធផលនៃការពិនិត្យរោគ និងបានទទួលសេចក្តីរាយការណ៍មួយ ។ សេចក្តីរាយការណ៍ ក៏ត្រូវគេផ្ញើទៅឲ្យអ្នកផ្តល់ជំនួយខាងការថែទាំសុខភាព ។ បើគេរកឃើញការបាត់បង់ការស្តាប់សម្លេង លោកអ្នកនឹងត្រូវគេបញ្ជូនទៅកាន់កម្មវិធីពិសេស និងធនធានតាមតំបន់ ។ មជ្ឈមណ្ឌលរៀបចំការស្តាប់សម្លេងរបស់កម្មវិធីពិនិត្យការស្តាប់សម្លេងទារកទើបប្រសូតប្រចាំរដ្ឋខាលីហ្វ័រញ៉ា (The California Newborn Hearing Screening Program's Hearing Coordination Center) ប្រហែលជាអាចទាក់ទង លោកអ្នក ដើម្បីជួយលោកអ្នក និងកូនរបស់លោកអ្នក ទៅរកកិច្ចការនានា ដែលលោកអ្នកត្រូវការ ។



## តើអ្នកណាចេញថ្លៃសម្រាប់ ការពិនិត្យវិនិច្ឆ័យមើលការស្តាប់សម្លេង (Diagnostic Hearing Evaluation)?

តម្លៃនៃការវិនិច្ឆ័យមើលការស្តាប់សម្លេង ត្រូវបានធានារ៉ាប់រងដោយគំរោងធានារ៉ាប់រងសុខភាពជាច្រើន ។ Medi-Cal and California Children Services (CCS) នឹងចេញថ្លៃចំពោះការពិនិត្យ សម្រាប់កុមារដែលមានសិទ្ធិទទួលជំនួយ ។ បើសិនជាលោកអ្នកមានសំណួរអ្វីមួយ អំពីការចេញថ្លៃចំពោះការពិនិត្យនេះ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់កូនលោកអ្នក ឬ អ្នកផ្តល់ជំនួយថែទាំសុខភាព ឬ ទូរស័ព្ទទៅលេខ 1-877-388-5301 ។

## ការកត់សំគាល់មើលការលូតលាស់របស់ទារក

បើសិនជា ការពិនិត្យវិនិច្ឆ័យរោគ បង្ហាញថា កូនរបស់លោកអ្នក មិនមានការបាត់បង់ខាងការស្តាប់សម្លេង, លោកអ្នកគួរតែបន្តឲ្យមានការពិនិត្យការស្តាប់សម្លេងរបស់កូនលោកអ្នក នៅពេលដែលកូនរបស់លោកអ្នកលូតលាស់ ។ ការធ្វើតេស្តការស្តាប់សម្លេងរបស់ទារកទើបប្រសូត គឺជាជំហានទីមួយ ក្នុងការពិនិត្យមើលការស្តាប់សម្លេង, ការនិយាយ, ការលូតលាស់ខាងភាសារបស់កូនលោកអ្នក ។ ទារកខ្លះ មានការបាត់បង់ខាងការស្តាប់សម្លេង ពេលក្រោយនៅក្នុងជីវិត, ហេតុដូច្នេះ វាជាការសំខាន់ណាស់ ដែលយើងត្រូវចាប់អារម្មណ៍ទៅលើការលូតលាស់ខាងភាសា និងការនិយាយរបស់កូនលោកអ្នក ។

## តើអ្វីទៅជា ការពិនិត្យវិនិច្ឆ័យមើលការស្តាប់សម្លេង (Diagnostic Hearing Evaluation)?

ការពិនិត្យវិនិច្ឆ័យមើលការស្តាប់សម្លេង គឺជាជំហានមួយទៀត ក្នុងការពិនិត្យមើលការស្តាប់សៈ -ម្លេងរបស់កូនលោកអ្នក ។ ការប៉ាន់មើលនោះ មានរួមទាំង- ការធ្វើតេស្តមួយចំនួន ដើម្បីឲ្យដឹងបានច្បាស់ អំពីការស្តាប- ់សម្លេងរបស់កូនលោកអ្នក ។ ការប៉ាន់មើលនោះ នឹងត្រូវ- បានធ្វើឡើងដោយវេជ្ជបណ្ឌិតខាងសម្លេង, ជាអ្នកវិជ្ជ- ាជីវៈខាងថែទាំសុខភាព ដែលមានវិជ្ជាឯកទេសខាងការស្តាប់សម្លេង ។

## តើគេធ្វើ ការពិនិត្យវិនិច្ឆ័យមើលការស្តាប់សម្លេង (Diagnostic Hearing Evaluation) តាមរបៀបណា?

នៅពេលដែលកូនរបស់លោកអ្នកកំពុងសម្រាក ឬកំពុងគេង គេនឹងប្រើឧបករណ៍ពិសេស ដើម្បីចាក់ស- ម្លេងតិចៗ តាមរយៈប្រដាប់ស្តាប់សម្លេង ដែលគេបា- នធ្វើយ៉ាងពិសេស ដើម្បីពិនិត្យមើលការស្ត- ាប់សម្លេងរបស់កូនលោកអ្នក ។ ដំណើរការណ៍ទាំងមូល គឺឥតឈឺចាប់ទេ ។ ការឆ្លើយតបរបស់កូនលោកអ្នក នឹងត្រូវគេថតជាអ៊ីឡិចត្រូនិក តាមរយៈដុំដាក់ក្នុងត្រចៀក ឬតាមរយៈខ្សែតូចៗ ដែលភ្ជាប់ដោយត្រនាប់ស្អិតៗ សម្រាប់ដាក់នៅលើក្បាល ។

ដោយសារត្រូវការធ្វើតេស្តជាច្រើនផង, ការពិនិត្យវិនិច្ឆ័យមើលការស្តាប់សម្លេង នឹងចំណាយពេលច្រើនជាងការពិនិត្យមើលការស្តាប់សម្លេងទារក ។ លោកអ្នកប្រហែលជាត្រូវនៅក្នុងការិយាល័យអស់រយៈពេលជាងមួយម៉ោង ឬប្រហែលជាត្រូវត្រឡប់មកវិញ សម្រាប់ការពិនិត្យជាលើកទីពីរ ។



## ពេលកំណត់ជួបដើម្បីពិនិត្យវិនិច្ឆ័យមើលការស្តាប់សម្លេង (Diagnostic Hearing Evaluation) របស់កូនលោកអ្នក ៖

ឈ្មោះកូន ៖

______________________________

ថ្ងៃទី និង ពេលកំណត់ជួប ៖

______________________________

ទីកន្លែងកំណត់ជួប ៖

______________________________

លេខទូរស័ព្ទសម្រាប់ទាក់ទងកន្លែងកំណត់ពេលជួប ៖

______________________________

(សូមទូរស័ព្ទ បើលោកអ្នកត្រូវការដាក់ពេលកំណត់ជួប សារថ្មី)

**កម្មវិធីពិនិត្យការស្តាប់សម្លេងទារកទើបប្រសូត ប្រចាំរដ្ឋខាលីហ្វ័រញ៉ា ៖**

គោលបំណងរបស់កម្មវិធីពិនិត្យការស្តាប់សម្លេងរបស់ទារកទើបប្រសូត ប្រចាំរដ្ឋខាលីហ្វ័រញ៉ា គឺដើម្បីសំគាល់ទារកណាដែលមានការបាត់បង់ខាង ការស្តាប់សម្លេង ហើយភ្ជាប់ពួកគេទៅជាមួ- យនិងកិច្ចការបំរើនានា មុនពេល មានអាយុប្រាំមួយខែ ។ កម្មវិធីនេះ មានមជ្ឈមណ្ឌលរៀប- ចំការស្តាប់សម្លេង (Hearing Coordination Centers) ដែលធ្វើការជាមួយគ្រួសារ, អ្នកផ្តល់ជំនួយខាងថែទាំសុខភាព និង មន្ទីរពេទ្យនានា ដើម្បីបញ្ជាក់ឲ្យច្បាស់ថា ទារកទាំងនោះបានទទួលជំនួយ ដែលពួកគេត្រូវការ ។ កម្មវិធីពិនិត្យ ការស្តាប់សម្លេងទារកទើបប្រសូតថ្មីៗ ប្រមូលពត៌មានអំពីការ ពិនិត្យមើលការស្តាប់សម្លេងរបស់កូនលោកអ្នក តាមច្បាប់សុខភាព និងសន្តិសុខ (Section 124119 of the Health and Safety Code) ។ មជ្ឈមណ្ឌលរៀប- ចំការស្តាប់សម្លេង អាចប្រើពត៌មាននេះ ដើម្បីជួយលោកអ្នក និងកូនរបស់លោកអ្នក ក្នុងការរកកិច្ចការបំរើដែលលោកអ្នកត្រូវការ ។ មជ្ឈមណ្ឌលរៀបចំការស្តាប់សម្លេង ប្រហែលជាទាក់- ទងលោកអ្នក អំពីកិច្ចការបំរើ ជាបន្តបន្ទាប់ ។

**សម្រាប់ពត៌មានបន្ថែម**
**អំពីកម្មវិធីពិនិត្យមើលការស្តាប់សម្លេងទារកទើបប្រសូត**
**សូមទូរស័ព្ទទៅលេខឥតគិតថ្លៃ 1-877-388-5301**


Children's Medical Services
714 P Street
Sacramento, CA 95814

Gray Davis
អភិបាលខេត្ត ប្រចាំរដ្ឋខាលីហ្វ័រញ៉ា
(Governor State of California)

Grantland Johnson
Secretary
Health and Human Services Agency

Diana M. Bonta', R.N., Dr. P.H.
Director
Department of Health Services



CMS Contract 98-16110

Publication Number 862

Rev. 3/2000 Cambodian